00832218

E217/1

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 07 / 08 / 2012
ម៉ោង (Time/Heure): 14:30
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

សាធារណៈ / Public

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

---

អង្គជំនុំជម្រះសាលាដំបូង

ថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ២០១២

**ជូនចំពោះ:** **ភាគីនៃសំណុំរឿង ០០២**

**ពី:** **ចៅក្រម និល ណុន ប្រធានអង្គជំនុំជម្រះសាលាដំបូង**

**ចម្លងជូន:** **លោក/លោកស្រីចៅក្រម និងមន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូង**

**កម្មវត្ថុ:** **ចម្លើយតបទៅនឹងសំណើសុំដាក់ឯកសារថ្មីមួយនៅក្នុងសំណុំរឿង ដោយអនុលោមតាមវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង (ឯកសារ** E217)

១. អង្គជំនុំជម្រះសាលាដំបូងបានទទួលសំណើមួយរបស់មេធាវីការពារជនជាប់ចោទ នួន ជា សុំដាក់ឯកសារថ្មីមួយទៅក្នុងសំណុំរឿង និងស្នើសុំការអនុញ្ញាតប្រើប្រាស់ឯកសារនេះក្នុងអំឡុងពេលដេញដោលសាក្សីនាពេលខាងមុខ ព្រមទាំងប្រើប្រាស់សម្រាប់ការធ្វើសេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោលផងដែរ (ឯកសារ E217)។ ឯកសារនេះគឺជាអត្ថបទមួយស្តីអំពី អ.វ.ត.ក ដែលបានផ្សព្វផ្សាយតាមបណ្តាញអ៊ិនធឺណែតនៅអំឡុងថ្ងៃទី ២៣ ខែ កក្កដា ឆ្នាំ ២០១២។ សំណើនេះត្រូវបានសរសេរដោយប្រើឃ្លាប្រយោគផ្សេងៗគ្នាថា "សំណើសុំដាក់ឯកសារថ្មី [...] ទៅក្នុងសំណុំរឿង" (ឯកសារ E217 កថាខណ្ឌ ១) និងសំណើសុំ "ទទួលយកអត្ថបទនេះជា "ភស្តុតាងថ្មី" (ឯកសារ E217 កថាខណ្ឌ ១២)។ អង្គជំនុំជម្រះយល់ឃើញថាសំណើនេះគឺជាសំណើសុំដាក់ឯកសារទៅចំពោះមុខអង្គជំនុំជម្រះ ដោយអនុលោមតាមវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង។

២. អនុលោមតាមវិធាន ៨៧ (៤) នៃវិធានផ្ទៃក្នុង អង្គជំនុំជម្រះអាចទទួលយកភស្តុតាងថ្មីដែលអង្គជំនុំ-ជម្រះយល់ថាមានប្រយោជន៍ដើម្បីបញ្ជាក់ការពិត ផ្អែកតាមលក្ខខណ្ឌទូទៅសម្រាប់ការទទួលយកភស្តុតាងដូចមានចែងក្នុងវិធាន ៨៧(៣)។ ជាក់ស្តែង វិធាន ៨៧(៣) ចែងថាអង្គជំនុំជម្រះអាចបដិសេធសំណើសុំឲ្យពិនិត្យភស្តុតាងក្នុងករណីអង្គជំនុំជម្រះយល់ថាជាភស្តុតាង "មិនជាប់ពាក់ព័ន្ធ ឬជាការស្នើសុំជាន់គ្នា"។

៣. មេធាវីការពារជនជាប់ចោទ នួន ជា យល់ថា "ចំណុចនីមួយៗក្នុងអត្ថបទនេះ (តាមការពិនិត្យដោយឡែក ឬរួមបញ្ចូលគ្នា) បង្កើតជាមូលដ្ឋានអង្គហេតុសម្រាប់ការដាក់សារណារបស់ខ្លួននៅចំពោះមុខអង្គជំនុំជម្រះ" (ឯកសារ E127 កថាខណ្ឌ ៥)។ បើទោះបីមេធាវីការពារជនជាប់ចោទ នួន ជា អះអាងថាអត្ថបទនេះមាន "សេចក្តីសន្និដ្ឋានថ្មីជាច្រើន" ក៏ដោយ (ឯកសារ E217 កថាខណ្ឌ ១០) ក៏មេធាវីការពារក្តីពុំបានព្យាយាមលើកយកអ្វីមកបញ្ជាក់អំណះអំណាងនេះ ឬបញ្ចូលអំណះអំណាងនេះជាមួយការទទួលស្គាល់មុនៗដែលបង្កើតជាមូលដ្ឋានអង្គហេតុនៃសេចក្តីសន្និដ្ឋានឡើយ។ ជាងនេះទៀត សេចក្តីសន្និដ្ឋាននានារបស់អ្នកសារព័ត៌មានពាក់ព័ន្ធនឹងភាពយុត្តិធម៌នៃកិច្ចដំណើរការនីតិវិធីនៅ អ.វ.ត.ក បើទោះបីវាជាសេចក្តីសន្និដ្ឋានថ្មីក៏ដោយ ក៏ពុំមានតម្លៃជាភស្តុតាង និងពុំសមស្របដើម្បីបញ្ជាក់អង្គហេតុដែលសេចក្តីសន្និដ្ឋានទាំងនោះចង់បញ្ជាក់ឡើយ។ ហេតុដូច្នេះ សេចក្តីសន្និដ្ឋានទាំងនេះពុំស្ថិតក្នុងវិសាលភាពនៃវិធាន ៨៧ (៤) នៃវិធានផ្ទៃក្នុងឡើយ។ តាម សំអាងហេតុទាំងអស់នេះ អង្គជំនុំជម្រះ យល់ឃើញថាអត្ថបទនេះពុំមានអង្គហេតុថ្មីឡើយ ហើយបានត្រឹមតែត្រួតជាន់គ្នាជាមួយឯកសារមុនៗ ដែលមេធាវីការពារក្តីបានដាក់ប៉ុណ្ណោះ។ អាស្រ័យហេតុនេះ អង្គជំនុំជម្រះបដិសេធសំណើរបស់មេធាវីការពារជនជាប់ចោទ នួន ជា។

៤. អង្គជំនុំជម្រះកត់សម្គាល់ឃើញថាអត្ថបទនេះ ត្រូវបានដាក់ក្នុងសំណុំរឿងដោយស្វ័យប្រវត្តរួចទៅហើយ ដោយហេតុថាអត្ថបទនេះត្រូវបានភ្ជាប់មកជាមួយឯកសាររបស់មេធាវីការពារជនជាប់ចោទ នួន ជា (ឯកសារ E217.1)។ ដើម្បីបញ្ចៀសមន្ទិល អង្គជំនុំជម្រះសូមបញ្ជាក់ថាអត្ថបទនេះពុំអាចត្រូវបានដាក់ជាភស្តុតាងនៅចំពោះមុខខ្លួនបានឡើយ (*ពោលគឺ* ពុំអាចប្រើប្រាស់ក្នុងអំឡុងពេលសួរសំណួរទៅសាក្សីនានា ឬលើកយកមកធ្វើជាភស្តុតាងពីសំណាក់ភាគីនានាក្នុងអំឡុងពេលនៃការធ្វើសេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោលឡើយ)។